ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អអក
EAC
អាជ្ញាធរអគ្គិសនីកម្ពុជា
លេខ ១៨៩ សរ-១៧ អអក

ភ្នំពេញ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧

# សេចក្តីសម្រេច
## ស្តីពីការកំណត់កម្រៃស្នើសុំអាជ្ញាបណ្ណ និងកម្រៃអាជ្ញាបណ្ណ សម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការិយបរិច្ឆេទ២០១៧

## អាជ្ញាធរអគ្គិសនីកម្ពុជា

- យោងច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងព្រះរាជក្រឹត្យស្តីពីការតែងតាំង **ឯកឧត្តម ទី នរិន្ទ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជាលេខនស/រកត/០៤០៨/៣៧៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥
- យោងអនុក្រឹត្យស្តីពីការកំណត់កម្រិតអតិបរមានៃកម្រៃអាជ្ញាបណ្ណ សម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា លេខ១៣១.អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០១
- យោងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ២២៦.សជណ.ឧស ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការឯកភាពជាគោលការណ៍លើគម្រោងថវិការបស់អាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ការិយបរិច្ឆេទ២០១៧
- យោងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ១០៦-សរ-១៧-អអក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការឯកភាពជាគោលការណ៍លើគម្រោងថវិការបស់អាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ការិយបរិច្ឆេទ២០១៧

## សម្រេច

**ប្រការ ១** - តាមសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលសម្រាប់ការិយបរិច្ឆេទ២០១៧ កម្រៃស្នើសុំអាជ្ញាបណ្ណដែលអ្នកស្នើសុំអាជ្ញាបណ្ណត្រូវបង់ មានដូចខាងក្រោមៈ

១- ចំពោះការស្នើសុំអាជ្ញាបណ្ណ ធ្វើសេវាកម្មអគ្គិសនីដែលមានលក្ខណៈអនុគ្រោះ (អគ្គិសនីជនបទ) កម្រៃស្នើសុំអាជ្ញាបណ្ណស្មើនឹងហាសិបពាន់រៀល (៥០,០០០រៀល) ក្នុងអាជ្ញាបណ្ណមួយ។

២- ចំពោះការស្នើសុំអាជ្ញាបណ្ណ ធ្វើសេវាកម្មអគ្គិសនីធុនតូច តូចជាងប្រាំរយគីឡូវ៉ាត់ (៥០០គីឡូវ៉ាត់) កម្រៃស្នើសុំអាជ្ញាបណ្ណស្មើនឹងមួយរយពាន់រៀល (១០០,០០០រៀល) ក្នុងអាជ្ញាបណ្ណមួយ។

៣- ចំពោះការស្នើសុំអាជ្ញាបណ្ណ ធ្វើសេវាកម្មអគ្គិសនីធុនមធ្យមពីប្រាំរយគីឡូវ៉ាត់ (៥០០គីឡូវ៉ាត់) ទៅបីពាន់គីឡូវ៉ាត់ (៣០០០គីឡូវ៉ាត់) កម្រៃស្នើសុំអាជ្ញាបណ្ណស្មើនឹងប្រាំមួយរយពាន់រៀល (៦០០,០០០រៀល) ក្នុងអាជ្ញាបណ្ណមួយ។

៤- ចំពោះការស្នើសុំអាជ្ញាបណ្ណ ធ្វើសេវាកម្មអគ្គិសនីធុនធំ លើសពីបីពាន់គីឡូវ៉ាត់ (៣,០០០គីឡូវ៉ាត់) កម្រៃស្នើសុំអាជ្ញាបណ្ណស្មើនឹងមួយលានរៀល (១,០០០,០០០រៀល) ក្នុងអាជ្ញាបណ្ណមួយ។

**ប្រការ ២** - កម្រៃស្នើសុំនេះ ត្រូវបង់តែម្តងគត់នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ។ ក្នុងករណីអាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចមិនផ្តល់អាជ្ញាបណ្ណឱ្យអ្នកស្នើសុំ អាជ្ញាធរអគ្គិសនីកម្ពុជានឹងបង្វែរកម្រៃនេះ ជូនទៅអ្នកស្នើសុំវិញ។

**ប្រការ ៣** - តាមសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលសម្រាប់ការិយបរិច្ឆេទ២០១៧ កម្រៃអាជ្ញាបណ្ណធ្វើសេវាកម្មដែលអ្នកកាន់អាជ្ញាបណ្ណត្រូវបង់សម្រាប់ការធ្វើសេវាកម្មតាមប្រភេទសេវាកម្មនីមួយៗ មានដូចខាងក្រោម:

១- ការផលិតអគ្គិសនីឬការទិញអគ្គិសនីពីក្រៅប្រទេស: ១.០៥រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងនៃថាមពលដែលបានធ្វើសេវាកម្មផលិតបញ្ចេញ ឬទិញចូលពីក្រៅប្រទេស

២- ការបញ្ជូនអគ្គិសនី : ០.៣៥រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងនៃថាមពលដែលបានធ្វើសេវាកម្មបញ្ជូនអគ្គិសនី

៣- ការចែកចាយ និងលក់អគ្គិសនី : ០.៤៥រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងនៃថាមពលដែលបានធ្វើសេវាកម្មចែកចាយ និងលក់អគ្គិសនី

៤- ការធ្វើសេវាកម្មលក់រាយ : ០.៣០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងនៃថាមពលដែលបានធ្វើសេវាកម្មលក់រាយ

៥- ការធ្វើសេវាកម្មក្រោមអាជ្ញាបណ្ណផ្សេងៗទៀតដែលមានចែងក្នុងមាត្រា២៩ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា : ០.១ភាគរយនៃថ្លៃសេវាកម្មនោះ។

**ប្រការ ៤** - ការកំណត់នេះ មានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទ២០១៧ ប៉ុណ្ណោះ។

**ប្រការ ៥** - លេខាធិការដ្ឋាននៃអាជ្ញាធរអគ្គិសនីកម្ពុជា មានភារៈកិច្ចផ្សព្វផ្សាយនិងជូនដំណឹងអំពីការកំណត់កម្រៃស្នើសុំអាជ្ញាបណ្ណនិងកម្រៃអាជ្ញាបណ្ណនេះ ដល់អ្នកស្នើសុំអាជ្ញាបណ្ណ និងអ្នកកាន់អាជ្ញាបណ្ណ ដើម្បីអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង រ៉ែ និងថាមពល "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ